នៅប្រទេសចិន រាប់ពាន់ឆ្នាំមុន ការកែនស្រីស្រស់ចូលទៅរស់នៅក្នុងវាំងបានក្លាយជារឿងធម្មតា។ ទោះបីជារជ្ជកាលមួយរលាយ រជ្ជកាលថ្មីកើតឡើង រឿងស្រីស្រស់នេះ នៅតែមិនបោះបង់។ ពាក្យចចាមអារ៉ាមអំពីរឿងស្នំបីពាន់នាក់ ដែលដេករង់ចាំឱ្យមានឱកាសបានជួបព្រះរាជា ឬក៏ព្រះចៅអធិរាជ គឺជារឿងពិត។

តាមឯកសារ ស្នំទាំងទាំងអស់នោះមានវ័យក្មេងៗ ខ្លះរហូតដល់ត្រឹមអាយុដប់ពីរឆ្នាំក៏ត្រូវឪពុកម្ដាយរៀបចំឱ្យចូលវាំង ដោយសារពឹងលើរូបសម្រស់និងវង្សត្រកូលគ្រួសារ ដែលមានសាច់សារលោហិតជាមន្ត្រីធំ សង្ឃឹមថាការប្រើសម្រស់ជាឱកាសមួយផ្សេង សម្រាប់ជួយជ្រោមជ្រែងគ្នាទៅវិញទៅមក បង្កើតឡើងជាអំណាចសម្រាប់វង្សត្រកូលរបស់ខ្លួន។ ដូច្នេះមានន័យថា ក្មេងស្រីទាំងអស់ដែលបានចូលទៅក្នុងរាជវង្ស ដោយប្រការណាមួយក្ដី មិនមែនជាកូនស្រីអ្នកធម្មតានោះអាចធ្វើបាននោះទេ លើកលែងតែក្រុមដែលត្រូវគេកែនទៅធ្វើជាអ្នកបម្រើដែលគ្រាន់តែត្រូវការមានកម្លាំងឬក៏មានជំនាញផ្នែកបោកគក់ ដេរប៉ាក់ តម្បាញ ធ្វើម្ហូបឬក៏ធ្វើស្រែចម្ការដាំដុះដំណាំបន្តិចបន្តួចបម្រើសេចក្ដីត្រូវការក្នុងវាំង។

ស៊ីនយុន គឺជាក្មេងស្រីតូចអាយុទើបតែដប់ប្រាំឆ្នាំ ដែលមានកម្លាំងខ្លាំង កាយសម្បទារឹងមាំត្រូវបានកែនចូលវាំងធ្វើជាអ្នកបម្រើដែរ ដោយសារត្រូវយកប្រាក់១ដំឡឹងមកលស់បំណុលម្ដាយដែលបានជំពាក់ពេទ្យព្យាបាលជំងឺ។

ចូលក្នុងវាំងនៅថ្ងៃដំបូង ស៊ីនយុនត្រូវបានបញ្ជូនទៅដំណាក់អ្នកបម្រើ។ នៅទីនោះគ្រប់គ្នាស្ថិតនៅក្រោមការគ្រប់គ្រងនៃលោកស្រីង៉ាវហាន។ លោកស្រីនេះជាគ្រូផង ជាអ្នកចាត់កម្លាំងឱ្យទៅបណ្ដាផ្នែកផ្សេងៗដែលត្រូវការអ្នកបម្រើផង។

ង៉ាវហានមានវ័យកណ្ដាល អាយុសាមប្លាយ មានជំនាញខ្ពស់ក្នុងការបង្វឹកអ្នកបម្រើជំនាន់ថ្មីៗនិងរៀបចំជាក្រុមៗ សម្រាប់បញ្ជូនទៅឱ្យដំណាក់ខាងក្រោយដើម្បីធ្វើការចាត់ចែងបម្រើហ្លួង ជាពិសេសធ្វើការនៅដំណាក់របស់ពួកអ្នកម្នាង ស្នំឯក ឬលោកស្រីទាំងឡាយណា ដែលជាស្រីស្អាតមកពីវណ្ណៈខ្ពង់ខ្ពស់រង់ចាំធ្វើជាអ្នកផ្គាប់ព្រះទ័យរបស់ព្រះរាជា។

កំពុងតែហាត់រៀបចំពែងនិងប៉ាន់ឱ្យត្រូវទិសក្បួនហុងស៊ុយតាមរាជវាំងនិយម នាងឮសំឡេងម្ចាស់ដំណាក់នេះ គឺលោកស្រីង៉ាវហាននិយាយត្រួសៗដូច្នេះឡើងថា៖

«ស៊ីនយុន ផ្ទៃមុខពងក្រពើ ភ្នែកធំៗមុតថ្លា បបូរមាត់តូច ច្រមុះស្រួចសក់វែងក្រាស់ ប៉ុន្តែនាងមិនចេះនិយាយស្តីច្រើនថែមទាំងមានអណ្តាតធំពិបាកក្នុងការហាស្តី ដូច្នេះហើយបានជាការងារអ្នកបម្រើ ផ្ទែកនៅផ្ទាល់ជាមួយនឹងដំណាក់ពួកអស់អ្នកនាងមិនសក្តិសមនឹងនាងឡើយ»

ថាដូច្នេះហើយ លោកស្រីង៉ាវហានបាននាំភ្ញៀវដើរហួសទៅ។

ក្មេងស្រីម្នាក់ទៀតជាអ្នកបម្រើមកពីស្រុកឆ្ងាយឈ្មោះហួង ប៉ុន្តែមាននិស្ស័យត្រូវរ៉ូវជាមួយស៊ីនយុន ដោយមានកន្លែងគេងក្បែរគ្នា បានស្ទុះមកខ្សឹបនិយាយប្រាប់ស៊ីនយុនថា៖

«យើងគ្មានលុយដើម្បីសូកគេ បានជាឯងមិនអាចទៅដំណាក់ខាងក្រោយដើម្បីបាននៅបម្រើអស់អ្នកអស់នាង!»

ដោយមិនយល់ស៊ីនយុន សួរវិញថា៖

«ហេតុអ្វីបានជាឯងចង់ឱ្យខ្ញុំទៅដំណាក់ខាងក្រោយ?!»

«ហើយពួកគេនោះនឹងឱ្យរង្វាន់ឯងច្រើន! មនុស្សពូកែប្រចាច់គក់ដូចជាឯង!»

យប់នោះស៊ីនយុនចូលសម្រាកតែម្នាក់ឯង បន្ទាប់ពីបានហាត់ការផ្ទែករៀបចំគ្រែនិងបោសសម្អាតរួចរាល់។ ចម្លែកត្រង់ថា ងាកទៅគ្រែរបស់មិត្តខ្លួន មិនឃើញនាងហួងទេ ក៏ស៊ីនយុនកើតក្តីឆ្ងល់យ៉ាងខ្លាំងព្រោះពេលនេះយប់ជ្រៅណាស់ទៅហើយ ហួងមិនដែលបាត់ដូច្នេះ។

រហូតដល់ភ្លឺនាងភ្ញាក់ដឹងខ្លួនឡើងក៏នៅតែមិនឃើញមិត្តខ្លួនមកគ្រែវិញទៀត។ លុះស្អែកឡើង ពេលបាយថ្ងៃត្រង់ក៏ស៊ីនយុន ឮពាក្យខ្សឹបខ្សៀវគ្នាថា នារីហួងដែលម្សិលមិញដែលបាននិយាយរឿងសូកប៉ាន់ ត្រូវបានលោកស្រីង៉ាវហានចាប់បាន ហើយពេលនេះ សង្ស័យថាមិនមានវាសនាបានត្រលប់មកដំណាក់អ្នកបម្រើវិញនោះទេ ព្រោះទៅយកទៅអប់រំនៅសាលាពិន័យ។

ស៊ីនយុន មិនដែលដឹងថារឿងនេះមានទាក់ទងអ្វីនឹងខ្លួននោះឡើយ ប៉ុន្តែមនុស្សគ្រប់គ្នានៅពេលដែលឃើញស៊ីនយុន ពួកគេខំចៀសចេញឆ្ងាយពីនាង។

យប់នោះដៃរនាងត្រូវបានលោកស្រីង៉ាវហាន បញ្ជាឱ្យទៅគក់ចង្កេះព្រោះគាត់ត្អូញចុកចង្កេះ។ រាត្រីពេលនេះ មេឃត្រជាក់ខ្លាំងណាស់ នាងពូកែគក់ហើយមិនមានសភាពងោកខ្ចិល

បញ្ជាក់ថា ស៊ីនយុនមានកម្លាំងខ្លាំង។ តាមពិតគាត់ចង់មកសាកល្បងចិត្តស៊ីនយុន បើនាងមានមាត់ច្រើនដូចហ្លួង ក៏គាត់មិនទុកក្បែរនាំគ្រោះថ្នាក់ដែរ។

ង៉ាវហានក៏សួរស៊ីនយុនថា៖

«មិត្តរបស់ឯង ឯងមិនឆ្ងល់ថាគេបាត់ទៅណាទេ?!»

«ខ្ញុំមិនដឹងទេលោកស្រី! តើលោកស្រីអាចប្រាប់ទេថាគេទៅបម្រើនៅដំណាក់ណាមួយ!»

ង៉ាវហានសើចចំអករួចឆ្លើយ៖

«ប្រហែលជាដំណាក់ខាងត្បូងហើយ!»

ថាហើយក៏លែងរវល់នឹងស៊ីនយុន ទុកឱ្យក្មេងស្រីគក់ច្របាច់រហូតដល់លោកស្រីនេះដេកលក់ដូចរាល់ដង ទើបនាងត្រលប់ទាំងហត់អស់កម្លាំងខ្លាំងទៅកាន់កន្លែងខ្លួន។

ទើបតែដើរបិទទ្វារដំណាក់ប្រធានបែរក្រោយស្ទាបនិងដើរបានពីរបីជំហានកាត់តាមសួនផ្ការំចេក ស្រាប់តែមានអារម្មណ៍ឃើញថាមានអ្នកណាម្នាក់កំពុងឈរពីចម្ងាយរង់ចាំនាង។

«ស៊ីនយុន!»

ជាសំឡេងហ្លួងហៅនាង។ ស៊ីនយុន ងាកឆ្វេងភ្លាមមើលស្គាល់ថាជាមិត្តរបស់នាងដែលនាងកំពុងតាមរកប៉ុន្តែមិនឃើញមុខទេដោយសារ ទីនោះងងឹតមិននៅជិតចង្កៀងព្យួរ។

«ឯងមែនទេម៉ីហ្លួង? ឯងទៅកន្លែងថ្មីហើយនឹកយើង មកលេងយើង?»

ស្រាប់តែក្មេងស្រីនោះនិយាយអន្លាយៗឆ្លើយមកវិញថា៖

«ស៊ីនយុន យើងរងាខ្លាំងណាស់ ចូរឯងយកភួយយើង ទៅដំណាក់ខាងត្បូងឱ្យយើងផង!»

ថាតែប៉ុណ្ណេះស៊ីនយុន ក៏ភ្ញាក់បះដៃបះជើងឡើងពីដំណេកឃើញខ្លួនឯងកំពុងតែដេកនៅជើងគ្រែរបស់លោកស្រីង៉ាវហានមិនទាន់ចាកចេញនៅឡើយ។

សុបិនរបស់នាងក៏បានធ្វើឱ្យលោកស្រីង៉ាវហានភ្ញាក់ព្រើតដូចគ្នា។ គាត់ក៏ក្រោកឡើងដែរ ប្រទេចរួចបណ្តេញស៊ីនយុនឱ្យចេញទៅដេក។ ពេលចេញទៅ ស៊ីនយុនមានឆ្លៀតមើលនៅតាមសួនក៏មិនឃើញមានអ្វីដូចក្នុងសុបិននោះដែរ។

រំលេងបានប៉ុន្មានថ្ងៃនាងក៏ឆ្លៀតសួរ នាងក៏ត្រូវបានគេបញ្ជូនឱ្យនាំយកកម្រាលពូកនិងភួយសូត្រ ដឹកតាមរទេះឆ្ពោះទៅកាន់ដំណាក់ខាងក្រោយ គឺទៅដំណាក់អ្នកម្នាងអើន ដែលទើបប្រសូត្របានបុត្រីភ្លោះ។

ពេលរៀបចំកន្លែងទារករួចព្រលប់ល្មម។

វិលមកដំណាក់អ្នកបម្រើវិញចាប់អារម្មណ៍ថា ពេលជិះកាត់កន្លែងមួយ ដែលមើលទៅស្ងាត់ជ្រងំ បាំងដោយដើមឈើធំៗ អ្នកបររទេះបានបង្កើនល្បឿនយ៉ាងលឿន ធ្វើឱ្យស៊ីនយុនភ័យខ្លាចតែធ្លាក់ពីលើរទេះខាងក្រោយព្រោះនាងអង្គុយនៅក្បែរច្រកចូល។

ខាងក្នុងរទេះពេញទៅដោយសម្ភារៈចាស់សម្រាប់យកទៅផ្លាស់ប្ដូរឱ្យពួកអ្នកបម្រើថ្មីប្រើ។

«ហេតុអ្វីបានជាបងប្រុសបររទេះលឿនម្ល៉េះ?» នាងសួរឡើង។

«ឯងមិនឃើញព្រលប់ហើយទេ?!»

«គ្រាន់តែព្រលប់តើយ៉ាងម៉េចទៅ?!»

«មេឃត្រជាក់ខ្លាំងណាស់!»

«មេឃត្រជាក់បងឯងពាក់អាវពីរបីជាន់ទៅវាចប់ទៅហើយ បើរត់លឿនយ៉ាងនេះខ្ញុំធ្លាក់ទៅច្បាស់ជាគ្រេចដៃខ្ញុំ ធ្វើម៉េចអាចផ្លាស់កម្រាលពូកនៅដំណាក់ខាងក្រោយបានទៀតទៅ!»

ធុញនាងពេក អ្នកបរទេសក៏ចូលដល់រឿងពិតជាក់ស្ដែង៖

«នោះគឺដំណាក់ខាងត្បូង! យើងខ្ជិលនិយាយជាមួយឯងច្រើនណាស់!»

នាងឆ្ងល់ណាស់ថា ហេតុអីបានជាអ្នកបរទេសដូចជាខ្លាចដំណាក់ខាងត្បូងយ៉ាងខ្លាំង? ដំណាក់នេះជាកន្លែងម៉ីហ្យួងប្រាប់ក្នុងសុបិនថានាងកំពុងរស់នៅ។

ឃើញគំនរភួយសូត្រ នាងចង់ទុកមួយឱ្យមិត្តណាស់ ព្រោះក្នុងសុបិន ចាំបានថាម៉ីហ្យួងរងា
។

នេះជាខែរងា បន្តិចទៀតនឹងធ្លាក់ព្រិលទៀតផងនៅខែក្រោយ។

ចិញ្ចឹមចិត្តបែបនេះ នៅមិនសុខទេ។ ពេលគេងឱបភួយ នាងតែងលបគិតថាមិនដឹងជាម្ចាស់ថ្មីនោះចិត្តបានឬមិនបានជាមួយម៉ីហួង រងាយ៉ាងនេះមិនឱ្យភួយនាង មិនឱ្យឡកម្ដៅនាងទេដឹង?

រហូតដល់បីថ្ងៃក្រោយមក ស៊ីនយុនក៏មានឱកាសសាជាថ្មីនៅក្នុងការប្រមូលកម្រាលពូក និងភួយចាស់ៗពីដំណើរខាងក្រោយដែលជាធម្មតាគេធ្វើមុននឹងហេមន្តរដូវចូលមកដល់។

នៅដំណាក់ធំរបស់ព្រះមហេសីនិងពពួកស្នំឯក អ្នកម្នាងធំៗ តែងមានទម្លាប់ដូរយកភួយសូត្រចាស់ៗដែលលែងប្រើ មកចែកចាយដល់ពួកស្រីវាំងដែលទើបនឹងចូលថ្មីៗ ហើយស្រូតយករបស់ថ្មីទៅដាក់ជូនពួកអ្នកធំទាំងនោះវិញ។

សាជាថ្មីនាងសម្គាល់ឃើញកន្លែងដែលមានដើមឈើខ្ពស់ៗសម្គាល់ថាដំណាក់ខាងត្បូង ស្រាប់តែលើកនេះ អ្នកបររទេះរអ៊ូឡើងថា «អូ កម្មពៀរហើយ ត្រូវមកនៅដំណាក់នេះ»។

ព្រោះអ្នកបើកបរនេះមិនមែនជាមនុស្សដដែលកាលពីថ្ងៃមុនទេ តែជាពូម្នាក់ពុកមាត់វែង។

ស៊ីនយុន ឮហើយក៏ងាកទៅសម្លឹងឃើញរទេះសេះធំមួយមានសេះ៦ មិនមែនជារទេះឥស្សរជនធម្មតាទេ។ បុរសនេះមិនបើករទេះគេចលឿនដោយសារពេលនេះមិនមែនជាពេលព្រលប់ ជាពេលព្រឹកថ្ងៃរះច្បាស់។

នាងពិតជាឃើញមានរទេះសេះស្នែងអភិជនដ៏ធំមួយដែលទំនងជាសែងកូនមន្ត្រីធំ ដោយសារមានសេះ៦នៅខាងមុខបង្ហាញពីភាពស្ដុកស្ដម្ភនៃម្ចាស់វា។

«តើអ្នកណាទៅនឹងត្រូវរើមកនៅដំណាក់ខាងត្បូងនេះ? ដំណាក់នេះខានមានគេនៅ៧ឆ្នាំមកហើយ!»

អ្នកបរទេសនិយាយបែបនេះម្នាក់ឯង តែប៉ះពាល់ចិត្តស៊ីនយុនជាខ្លាំងព្រោះនាងនឹកដល់ម៉ីហួង។

«មានដំណាក់ដែលគេមិននៅ៧ឆ្នាំដែរ?»

«ត្រូវហើយ ពីព្រោះល្បីថាចាប់តាំងពីអ្នកម្នាងសៀវបានស្លាប់ទៅ នៅទីនោះតែងតែមានរឿងរំខាន គ្មានអ្នកណានៅបានទេ!»

សុីនយុនចំហមាត់ឆ្ងល់៖

«អ្នកម្នាងសៀវជាអ្នកណាទៅ?!»

«យី អើរុី ក្មេងស្រីល្ងង់នេះ! អ្នកម្នាងសៀវ គឺជាកូនស្រីពៅរបស់មេទ័ពសៀវ! ឯងកុំមាត់ឱ្យសោះ ប្រយ័ត្នដាច់ក្បាល!»

«ហេតុអ្វីបានជាគាត់ស្លាប់? ហើយអ្នកម្នាងសៀវជាអ្នកនៅដំណាក់ខាងត្បូង?»

«ត្រូវហើយ! គាត់គឺជាសំណព្វព្រះទ័យរបស់ព្រះអង្គ! ពេលដប់ឆ្នាំមុន គាត់ចូលវាំងភ្លាម ក៏មានអំណាចខ្លាំងណាស់ ដោយសារតែមានឪពុកជាមេទ័ពនៅព្រំដែនខ្លាំងពូកែ មានទ័ពក្នុងដៃរាប់ម៉ឺន ថែមទាំងគាត់មានរូបសម្រស់ស្អាត ប៉ុន្តែក្រោយមកឮសូរថាគាត់បានស្លាប់នៅពេលដែលសម្រាលកូន ការស្លាប់ទាំងកូនទាំងម្ដាយជាព្រលឹងតែហោង ធ្វើឱ្យគេប្រែក្លាយដំណាក់របស់គាត់ជាកន្លែងពាក្យចចាមអារ៉ាមខ្មោច! មិនមាននរណាម្នាក់ហ៊ានទៅស្នាក់នៅទៀតទេ ដំណាក់អ្នកម្នាងសៀវ បានបិទទ្វារក្លាយទៅជាកន្លែងដែលអ្នកណាៗក៏ខ្លាចមានរឿង!»

«អុីចឹងបានជាថ្ងៃមុនអ្នកបរទេសមកជិតនេះ ខំបរចេញយ៉ាងលឿនសឹងគ្រេចចង្កេះ!»

«អើ ពួកអ្នកបម្រើដែលធ្លាប់ចេញចូលដំណាក់នេះ និយាយថា គ្រាន់តែដើរកាត់ពីចម្ងាយក៏ត្រូវលងដែរ!»

រទេះហួសទៅមុខសុីនយុន នៅតែមិនអស់ចិត្តចំពោះអ្វីដែលនាងបានឮនិងបានឃើញ។

«ចុះស្នែងសេះ៦នេះ ជាអ្នកណា?»

«យើងមិនដឹងទេ! ឯងសួរយើងយើងសួរអ្នកណា?!»

«បោះបង់ចោលជិតដប់ឆ្នាំតើឱ្យគាត់ចូលមករស់នៅម្ដេចនឹងបាន?!»

«ឯងមិនដឹងទេ ព្រះរាជានៅតែស្រឡាញ់អ្នកម្នាងសៀវជានិច្ច! ព្រះអង្គមិនចង់ឮចចាមអារ៉ាមអីទេអាចនឹងមានទោសស្លាប់! ព្រះអង្គតែងឱ្យគេមកបោសសម្អាតថែទាំ ធ្វើដូចកាលអ្នកម្នាងនៅរស់ដែរ! ណ្ហើយ ឯងអណ្ដាតធំផងត្រឡាន់ផង កុំមាត់វែង ចូរចេះរក្សាជីវិត ត្រូវចាត់ទុកថាយើងមិនបាននិយាយអ្វីទាំងអស់ ហើយឯងថ្ងៃនេះជិះកាត់ក៏មិនបានឮឬឃើញអ្វីទៅចុះ សូម្បីតែឮក៏អាចមានគ្រោះថ្នាក់ដែរ!»

គិតចុះគិតឡើងស៊ីនយុនមានអារម្មណ៍ថា រឿងមិត្តរបស់នាងដែលបាត់ខ្លួន ហើយនាងគិតថា ទៅរស់នៅដំណាក់ខាងត្បូងមិនមែនជាការពិតទេ ទីនោះគួរឱ្យខ្លាចមានអ្នកណានៅបានទៅ?

ប្រហែលយប់នោះ នាងត្រូវអ្នកង៉ាវហានកុហក បានជាយល់សប្តិមួយភ្លែតក៏ត្រូវស្រមើស្រមៃឃើញម៉ីហ្វុងមកនិយាយសុំភួយយកទៅដំណាក់ខាងត្បូង។

ពេលមកដល់កន្លែងត្រូវរើភួយសូត្រ ស៊ីនយុនធ្វើការជាមួយក្រុមអ្នកបម្រើច្រើនទៀតរបស់ស្នំឯកអ៊ែ ជាមនុស្សមកពីស្រុកហ៊ីប៉ៃ។ ក្រុមនេះមានគ្នាបួននាក់ហើយនិយាយស្តីចេចចាចដោយសេរី ព្រោះស្នំឯកអ៊ែជាមនុស្សស្លូត មានវ័យត្រឹមតែ១៦ឆ្នាំ។

«នែ៎ ឯងដឹងទេ មានព្រះនាងមកពីនគរចំណុះយាងមកដល់ដំណាក់ខាងត្បូង!»

«ឱ! ហេតុអ្វីបាបកម្មត្រូវនៅកន្លែងនោះ?!»

«ព្រោះគេមកពីនគរផ្សេងមិនដឹងរឿង អ្នកម្នាងសៀវស្លាប់និងមិនដឹងប្រវត្តិដំណាក់នោះ ហើយឮថាជាព្រះនាងដែលមានរូបស្អាតខ្លាំងបានជាព្រះមហេសីមិនពេញចិត្ត រកវិធីធ្វើយ៉ាងណាឱ្យត្រូវទៅរស់នៅកន្លែងអពមង្គល!»

«ព្រះមហេសីពិតជា.....»

«ល្មើយ....ឯងចង់រក្សាជីវិតឈប់នាំគ្នានិយាយ! នៅខាងក្រៅមានស្រីបម្រើមកពីដំណាក់ង៉ាវហានផង ប្រយ័ត្នគេឮ»

ស្នំអ៊ែហាមប្រាមហើយពួកគេក៏ស្ងាត់មាត់ច្រៀបវិញ។

ស៊ីនយុននៅខាងក្រៅណេះ ខំធ្វើការធម្មតាធ្វើដូចមិនបានឮអ្វីទាំងអស់ ប៉ុន្តែធាតុពិតទៅរឿងដំណាក់ខាងត្បូងនៅតែលាន់ឮគួរឱ្យឆ្ងល់ក្នុងអារម្មណ៍នាង។

មួយខែក្រោយមក រឿងហេតុកើតឡើងប្លែកនៅដំណាក់អ្នកបម្រើ។

មួយរយៈក្រោយនេះ ដោយសារតែអ្នកស្រីង៉ាវហានបានបាត់ខ្លួនពីដំណាក់ អ្នកបម្រើក្មេងៗចូលថ្មីទាំងអស់ ត្រូវបានគេឱ្យរៀនសៀវភៅដោយខ្លួនឯងឬឱ្យពួកអ្នកមុនៗបង្រៀនវិធីប្តូរកម្រាលពូក វិធីរៀបប៉ាន់តែនិងតុកៅអី ដុតភ្លើងទៀន។ល។

គ្មានអ្នកណានិយាយថា អ្នកស្រីង៉ាវហានបាត់ទៅណានោះទេ។

ព្រលប់មួយស៊ីនយុនកំពុងហូបបាយ ស្រាប់តែឃើញអ្នកស្រីង៉ាវហានលេចមុខ ហើយបក់ដៃហៅនាង។

នាងដាក់ចានចុះនិងស្ទុះទៅតាមរកគាត់ ព្រោះបាត់គាត់ប៉ុន្មានថ្ងៃហើយ។ គាត់មិនមាត់មិនក បង្គាប់ឱ្យនាងឡើងរទេះទៅជាមួយ។ រទេះបានដើរទៅត្រុកៗអ្នកង៉ាវហានមិននិយាយមិនស្តីអ្វី ធ្វើឱ្យស៊ីនយុនកាន់តែឆ្ងល់ឡើង។

មិនយូររទេះបានបត់តាមផ្លូវទៅដំណាក់ខាងក្រោយ តែបែរជាមកឈប់នៅក្រៅម្ដុំព្រៃក្រាស់។

ទោះស៊ីនយុនខំរៀបឫកប៉ុនណានៅតែមិនអាចលាក់លៀមសេចក្ដីភ័យខ្លាចរបស់នាងពេលបានឃើញដំណាក់ខាងត្បូងព្រោះពេលនេះយប់ហើយ។ មិនស្មានថា អ្នកង៉ាវហានបានឱ្យអ្នកបររទេះឈប់នៅក្បែរក្លោងទ្វារដំណាក់ដែលស្ងាត់ជ្រងំ មានចង្កៀងព្យួរមួយធំយ៉ាងលឿងវិចិត្រ។

«ដំណាក់ខាងត្បូង?» ស៊ីងយុនបាននិយាយឡើង។

«ត្រូវហើយ ទីនេះស្អាតណាស់!»

ង៉ាវហាននិយាយអន្លាយៗជាមួយនាង។

ស៊ីនយុនមិនដឹងថា អ្នកស្រីនេះមានការអ្វីនៅដំណាក់ខាងត្បូង តែនាងអរណាស់ប្រសិនបានជួបម៉ីហ្សួង។

«អ្នកស្រីង៉ាវ តើម៉ីងហ្សួងនៅទីនេះទេ?»

នាងសួរនេះធ្វើឱ្យគាត់ក្ដិចនាងហើយអូសដៃចូលទៅទាំងមិនព្រមផ្ដល់ចម្លើយ។ ពីក្លោងទ្វារទៅក្នុងប្រាសាទពិតជាឆ្ងាយគួរសម គាប់ជួនមេឃព្រាលៗព្រោះព្រិលធ្លាក់តិចៗ ល្ងាចនេះពិតជាត្រជាក់ខ្លាំងណាស់។

មិនយូរទេមានអ្នកបម្រើប្រុសម្នាក់បង្ហាញខ្លួនទឹកមុខកាចមានពុកចង្កាស្រម៉ូម។

«ពីរនាក់អាចនៅចាំនៅទីនេះសិន!»

ជននោះបង្គាប់។ ង៉ាវហានបាននាំស៊ីនយុនឈររង់ចាំទាំងរងាញាប់ញ័រ។ ទោះបីជាយ៉ាងណា ផ្អែកលើសភាពពិត ស៊ីនយុនយល់ថា ទីនេះស្អាតនិងរៀបរយ មិនសមជាកន្លែងគ្មានមនុស្សនៅដល់៧ឆ្នាំនោះទេ។

ប្រហែលមកពីអ្នកមកដល់ជាព្រះនាង បានមានការរៀបចំសាជាថ្មីយ៉ាងប្រណីតបែបនេះ។

«ទាំងពីរនាក់មកតាមខ្ញុំ!»

នាងនិងប្រធានបានត្រូវអាមាត្រនោះនាំចូលទៅក្នុងបន្ទប់ជំនុំធំ ដែលមានរចនាប័ទ្មរៀបចំយ៉ាងស្កុកស្គម្ភ។ ទាំងវាំងនួនសូត្រនិងកម្រាលព្រំ ស៊ីនយុនមិនដែលឃើញមានទេ។

នាងមិនដែលទៅកាន់ដំណាក់ព្រះមហេសី បានជាមិនអាចប្រៀបធៀបបានថា ទីនេះជារាជដំណាក់អ្នកមានម្នាងល្អប៉ុណ្ណឹង ចុះទម្រាំនៅកន្លែងព្រះមហេសី?

«ឯងឈរនៅណោះ!»

អ្នកង៉ាវហានបញ្ជាលើស៊ីនយុន នាងក៏ឈរទ្រឹងកណ្តាលសសរស្តម្ភបន្ទប់ សម្លឹងគ្រប់យ៉ាងចំហមាត់។

នៅដំណាក់អ្នកបម្រើ នាងរៀនដាំជើងភ្លើងទៀន តែមិនដែលឃើញជើងទានមាសសុទ្ធ និងប្រាក់សុទ្ធចិញ្ចាចបែបនេះដែរ។

តាមបង្អួចមិនអាចមើលឃើញខាងក្រៅ ព្រោះមានផ្ទាំងគំនូរប៉ាក់យ៉ាងមានតម្លៃ ជាសត្វនាគនិងហង្សដែលគេច្រើនប្រើនៅក្នុងដំណាក់ស្តេចតែប៉ុណ្ណោះ។

នេះហើយជាសួយសាអាករនៃរាជបុត្រីមកពីព្រំដែនទេដឹង?

ពេលនោះទាញអារម្មណ៍មកវិញ ស៊ីនយុនហាក់ឃើញប្រធានផ្ទះអ្នកបម្រើលោកស្រីង៉ាវហានកំពុងអង្គុយផ្ទាល់លើព្រំ ឆ្ងាយពីនេះដោយបែរខ្នង។

នៅពីមុខគាត់មានអាសនៈមានមនុស្សអង្គុយ តែឆ្ងាយពេកស៊ីនយុនមិនអាចមើលឃើញច្បាស់។

អ្នកង៉ាវហានដូចជាបានទទួលអ្វីមួយ មួយកញ្ចប់ទំនងដូចជាប្រាក់ ពីដៃអ្នកណាម្នាក់ដែលនៅម្ខាងគាត់ ហើយគាត់ឱនលំទោនសំពះគេញឹកញាប់រួចក្រោកចេញមកយ៉ាងលឿន។

មកដល់ពីមុខនាងគាត់បោយដៃហៅនាងចូល។

ស្ត្រីម្នាក់វ័យចំណាស់មុខមាំស្លេក គ្មានស្នាមញញឹម បានបង្ហាញខ្លួនពៅក្រោយខ្នងរបស់ស៊ីនយុន។

«នេះគឺជាមីងទៀង ជាអ្នកគ្រប់គ្រងចំណាស់ជាងគេនៅដំណាក់ព្រះនាងដាកីនេះ! តទៅឯងត្រូវនៅបម្រើព្រះនាង ត្រូវរៀនពីមីងទៀងគ្រប់សព្វដែលគាត់ប្រាប់ឯង!»

ស៊ីនយុនទើបនឹងដឹងថា ព្រះនាងដាកីមកពីឆ្ងាយខ្វះអ្នកបម្រើចង់បានអ្នកដែលមានភាពចំណាប់ចំនួន បានជាល្ងាចនេះង៉ាវហានត្រូវបានគេនាំយកមកថ្វាយ។

សូម្បីព្រះនាងមានព្រះភក្ត្របែបណាស៊ីនយុនមិនដែលដឹងទេ។

អ្នកង៉ាវហានបានបាត់ទៅទាំងយប់ ទុកឱ្យស៊ីនយុននៅតែឯងដោយព្រួយបារម្ភ មិនមានសូម្បីតែសម្លៀកបំពាក់ផ្សេងមកដើម្បីផ្លាស់។

«ឯងមិនបាច់ភ័យទេ នៅទីនេះយើងនឹងក្លាយទៅជាគ្រួសារមើលថែគ្នាទៅវិញទៅមក!»

នេះគឺជាពាក្យអ្នកបម្រើជំនិតនៃព្រះនាងនិយាយរដឺនៗតាមបែបជាអ្នកនៅភាគខាងជើងដែលមិនដែលមកដល់ដីកណ្ដាល។

ស៊ីនយុនត្រូវបានអ្នកបម្រើនោះចាត់ចែងឱ្យទៅរកបន្ទប់របស់ខ្លួន។

ជាបន្ទប់មួយនៅពីក្រោយដំណាក់ទទួលភ្ញៀវនេះមានបីបន្ទប់ ចំណែកបន្ទប់នាងនៅចុងគេផុត។

«ខ្ញុំនឹងចែកខោអាវស្បែកជើងថ្មីឱ្យឯង! ពេលនេះឯងឆាប់ដេកនិងងើបពីព្រឹកជួយខ្ញុំរៀបចំក្រយាស្ងោយសម្រាប់ព្រះនាងនិងជូតដុសប្រាសាទនេះ!»

ស៊ីនយុនមិនត្អូញត្អែរចំពោះការងារទាំងនេះនោះទេដ្បិតតែប្រាសាទនេះមើលទៅធំខ្លាំងសក្តិសមទៅនឹងកេរ្តិ៍ឈ្មោះដែលថា អ្នកម្នាងសៀវពីមុនជាម្ចាស់កន្លែងនេះត្រូវបានសព្វព្រះទ័យដោយព្រះមហាក្សត្រ គ្រប់យ៉ាងថ្មី ប្រណីតមិនពិបាកក្នុងការសម្អាតឡើយ។

យប់នោះខ្យល់ត្រជាក់យ៉ាងខ្លាំង តែនៅលើគ្រែស៊ីនយុនមានខ្នើយមួយនិងភួយក្រាស់ពីរ។ គ្រប់យ៉ាងប្រសើរជាងនៅឯដំណាក់អ្នកបម្រើ។

ស្ត្រីម្នាក់នោះបានចូលមកជួបនាងជាមួយនឹងទៀនមួយដើមធំ ហើយផ្ដាំប្រាប់នាង ថាចូរនាងដណ្ដប់ភួយកុំឱ្យផ្ដាសាយ នាំឱ្យប៉ះពាល់ដល់ក្រយារបស់ព្រះនាង ហើយដំណាក់នេះមានវិន័យតឹងរឹងពេលយប់ គឺនៅពេលចូលគេង គឺត្រូវនៅក្នុងបន្ទប់មិនអាចឱ្យដើរចេញចូលផ្ដេសផ្ដាសទៅណាមកណាបានសេរីនោះទេ។

នោះជាយប់ដំបូងបន្ទាប់ពីពេលចូលវាំង ដែលមានម្ចាស់ប្រកបដោយចិត្តធម៌វ័យក្មេងហើយឱ្យភួយដ៏កក់ក្ដៅ ក៏ជាយប់ដំបូងដែលស៊ីនយុនមិនរងាក្នុងរាជវាំងដ៏ធំធេងនេះ។

នាងគេងលក់យ៉ាងសុខសាន្ត ចិញ្ចឹមចិត្តថាស្អែកនឹងត្រួតពិនិត្យពាសពេញប្រាសាទដ៏ល្បីនេះម្ដង។

ស្រាប់តែ....សំឡេងយំខ្សាវៗបានដាស់នាងឱ្យភ្ញាក់ឡើងស៊ើងមមើង....ស៊ីនយុនមានអារម្មណ៍ថាអ្វីៗគឺជាសុបិន ប៉ុន្តែនាងបែរជាឮសូរសំឡេងយំច្បាស់ទៅៗរហូតដល់គេងលេងលក់ស្វាងថៃសតែម្ដង។

ដោយសេចក្ដីងឿងឆ្ងល់និងបានទទួលការហាមមិនឱ្យចេញពីបន្ទប់ពេលយប់ នាងបានក្រោកដើរទៅក្បែរបង្អួចហើយរុញបង្អួចទៅក្រៅ បម្រុងពិនិត្យមានអារម្មណ៍ថា នៅក្រៅបង្អួចគឺសុទ្ធតែជាសួនដែលពេញទៅដោយផ្កាវីកស្គុះស្គាយក្រអូបសាយ មិនមានអ្នកណាបេះដោយសារគ្មាននរណាហ៊ានឆ្លងកាត់ទីនេះ។

ប៉ុន្តែនៅក្រោមពន្លឺព្រះចន្ទភ្លឺថ្លានាងបានឃើញអណ្ដូងមួយដែលប្រាកដថា សំឡេងយំលាន់ចេញពីម្ដុំនោះ។ នាងមានអារម្មណ៍ឆ្ងល់ថាហេតុអ្វីបានជាមានសំឡេងយំនៅក្បែរអណ្ដូង ឬមួយក៏ព្រះនាងពិតជានឹកព្រះរាជនគរ មិនទម្លាប់និងទឹកដីនេះ ឬក៏ប្រាសាទនេះស្វាត់ខ្លាំងពេក?

មានអារម្មណ៍ដូចជាខ្លាច ស៊ីនយុនប្រញាប់បិទបង្អួចវិញ ហើយសំឡេងយំក៏រលាយបាត់។

នាងចូលមកសម្ងំគេងដោយស្ដាយថា មិនបានសួរនាំអំពីស្ត្រីបម្រើម្នាក់ទៀតតើបន្ទប់គាត់នៅកន្លែងណានាងអាចនឹងទៅអង្គុយនិយាយជាមួយគាត់បានប៉ុន្តែដោយសារវិន័យដែលគាត់ទើបតែប្រាប់នាងមិនហ៊ាននោះទេ។

ស្អែកឡើងមាន់រងាវភ្លាមស៊ីនយុនក្រោកចាកចេញគ្រែឆ្ពោះទៅកាន់បន្ទប់បាយក៏ឃើញស្ត្រីដដែលកំពុងតែបែរខ្នងកិនសណ្ដែក។

«តើខ្ញុំអាចធ្វើអ្វីជួយបាន?!»

«ឯងធ្វើអ្វីទាំងអស់ដែលអាចធ្វើទៅ!»

គាត់ឆ្លើយតែប៉ុណ្ណោះធ្វើឱ្យស៊ីនយុនមានអារម្មណ៍ថា គាត់ដូចជាមិនសប្បាយចិត្តនឹងនាង។ ស៊ីនយុនមិនហ៊ាននិយាយអំពីសំឡេងយំនិងអណ្ដូងកាលពីយប់មិញនោះទេ ដោយឃើញគាត់បែបនេះ។

ភ្លាមនោះនាងក៏ដើរប្រុងចាកចេញ ទៅស្រាប់តែស្ត្រីនោះប្រាប់ថា៖

«ហេ ឯងយកចាសមាសមកឱ្យយើង យើងរៀបចំទឹកតែយកទៅថ្វាយព្រះនាង!»

ស៊ីនយុនធ្វើតាមចង្អុលដៃគាត់ ក៏បែរខ្លួនទៅយកចាសមាសមួយចេញពីទូឈើ ក្រោយខ្នង ។

ក្នុងទូនោះពេញដោយចាននិងកែវគជ់ជាចម្លាក់មកពីបុរាណយ៉ាងគួរឱ្យជញ្ជក់មាត់សរសើរ ។

នាងដាក់ចាសមកមុខស្ត្រីនោះ ហើយគាត់ក៏បញ្ជា៖

«ដាក់នៅណឹងចុះ!»

គាត់មកឈរបែរខ្នងបាំង ហាក់លាក់លៀម មិនចង់ឱ្យស៊ីនយុនឃើញ ពែងនិងប៉ាន់របស់គាត់ ស្រាប់តែច្រមុះនាងមានក្លិនអ្វីមួយចម្លែក មិនមែនជាតែ ឬភេសជ្ជៈថ្នាំនាងធ្លាប់ស្គាល់សោះ។

នេះគឺជារឿងមួយដែលធ្វើឱ្យនាងខំជំទើតជើងអើតមើល ប៉ុន្តែស្ត្រីនោះបែរមកឃ្វាំង ធ្វើភ្នែកក្រឡោតបណ្ដេញនាងចេញ។

«ទៅធ្វើការរបស់ឯងទៅ!»

នេះជារឿងថ្មីមួយទៀតហើយដែលធ្វើឱ្យស៊ីនយុនចង់ដឹងខ្លាំងណាស់ថា តើព្រះនាងមកពីតំបន់ព្រំដែននិយមពិសារតែអ្វីនៅពេលព្រឹកហេតុអ្វីបានជាអ្នកបម្រើជំនិតរបស់គាត់លាក់លៀមជាខ្លាំង?

ពេលបោសជូតដំណាក់រួច ស៊ីនយុនទទួលបាននំប៉ាវបីពីស្ត្រីដដែល។ នាងអង្គុយហូបតែម្នាក់ឯងក្បែរសសរខាងក្រៅបន្ទប់គេង។

ពីចម្ងាយក៏ឃើញអាមាត្យប្រុសមុខមាំ ទទួលបានចានបាយនិងម្ហូបពីអ្នកបម្រើនោះទៅអង្គុយហូបម្នាក់ឯងនៅក្រោមដើមឈើ។ ពួកគេមិននិយាយស្ដីនោះទេ។

ចំណែកព្រះនាងដ៏ស្រស់ស្អាតគឺ ស៊ីនយុនមិនដែលបានឱកាសជួបព្រះភក្ត្រសោះតែម្ដង។